# សរុបព័ត៍មានសំខាន់ៗពាក់ព័ន្ធនឹងជំងឺខូវីដ ១៩ នាថ្ងៃទី ១៧ ខែ មីនា

March 17, 2020, 4:34 PM

**ចែករម្លែក**

0
Shares

**ដោយៈមេសា/ ភ្នំពេញ:** យោងតាមសេចក្តីប្រកាសជាបន្តបន្ទាប់របស់ក្រសួងស្ថាប័ននានា ពាក់ព័ន្ធនឹងស្ថានភាពជំងឺ កូរ៉ូណាវីរុស ឬ COVID-19 មានដូចតទៅ ៖

**រាជរដ្ឋាភិបាល ប្រកាសបង្កើតគណៈកម្មអន្តរក្រសួង ដើម្បី ប្រយុទ្ធនឹងជំងឺ ខូវីដ ១៩**

ដោយមានរដ្ឋមន្ត្រីក្រសួងសុខាភិបាលជាប្រធាន និង មានមន្ត្រីជាន់ខ្ពស់មកពីក្រសួង ១៤ ផ្សេងទៀតជាអនុប្រធាន និង សមាជិក ។

គណៈកម្មការនោះ មានកាតព្វកិច្ចសំខាន់ៗ ៦ ចំណុចគឺ៖ -រៀបចំផែនការឆ្លើយតបជំងឺ ខូវីដ ១៩ , អនុវត្តសកម្មភាពតាមផែនការដែលបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល , តាមដានត្រួតពិនិត្យ និង វាយតម្លៃ ការអនុវត្ត នៃ ការប្រយុទ្ធនឹងជំងឺខូវីដ ១៩ , លើកទិសដៅប្រតិបត្តិជាយថាហេតុតាមស្ថានភាពជាក់ស្តែង នៃ ការរាតត្បាតរបស់ជំងឺខូវីដ ១៩ , រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីការវិវត្តន៍ នៃ ជំងឺខូវីដ ១៩ និង ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

សេចក្តីប្រកាសដដែលបើកផ្លូវថា គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការបច្ចេកទេសផ្សេងទៀត តាមការចាំបាច់ ។

**ករណីឆ្លង និង យកទីតាំង ២ សម្រាប់អ្នកជំងឺ ខូវីដ ១៩-បិទ KTV និង រោងភាពយន្ត**

គិតត្រឹមម៉ោង ៤ និង ៣០ នាទីព្រឹកថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២០ នេះ កម្ពុជា រកឃើញអ្នកឆ្លងជំងឺ ខូវីដ ១៩ សរុប ២៤ ករណី ។ ប៉ុន្តែក្រសួងសុខាភិបាលបានហៅថា នោះមិនមែនជាករណីផ្ទុះជំងឺ ខូវីដ ១៩ នៅកម្ពុជា ទេ ដោយសារករណីទាំងនោះ សុទ្ធតែជាអ្នកឆ្លងនៅប្រទេសផ្សេង ហើយទើបចូលមកកម្ពុជា តែប៉ុណ្ណោះ ។

នៅក្នុងសេចក្តីប្រកាសជាបន្តបន្ទាប់របស់ខ្លួន ចុះថ្ងៃទី ១៦ និង ១៧ ខែ មីនា ឆ្នាំ ២០២០ នេះ ក្រសួងសុខាភិបាល កម្ពុជា បានអះអាងថា បានយកទីតាំងចំនួន ២ ទៀតសម្រាប់ថែទាំ និង ព្យាបាលអ្នកជំងឺខូវីដ ១៩ គឺ ៖

១. អតីតមណ្ឌលសុខភាពចាក់អង្រែ ក្នុងសង្កាត់ ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលនៅទីនោះ មានចំណុះ ១០០ គ្រែ ។

២. សណ្ឋាគារ Great Duke ( អតីតសណ្ឋាគារ អាំងទែរកុងទីណង់តាល់ ) ។




សណ្ឋាគារ Great Duke និង មណ្ឌលសុខភាពចាក់អង្រែ ដែលក្រសួងសុខាភិបាលប្រកាសយកធ្វើជាទីតាំងថ្មីសម្រាប់ថែទាំ និង ព្យាបាលអ្នកជំងឺ ខូវីដ ១៩ ( រូប: ក្រុមការងារ )





ក្រសួងសុខាភិបាល ក៏បានបញ្ជាក់បន្ថែមថា កន្លងមក ក្រសួងបានរៀបចំកន្លែងថែទាំ និង ព្យាបាលអ្នកជំងឺ ខូវីដ ១៩ នៅ

មន្ទីរពេទ្យមិត្តភាពខ្មែរ-សៅវៀត មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ មន្ទីរពេទ្យជ័យវរ្ម័នខេត្តសៀមរាប និង នៅមន្ទីរពេទ្យទូទាំង ២៥ រាជធានីខេត្ត ។

ក្រសួងសុខាភិបាលកម្ពុជា បានចេញសេចក្តីប្រកាសមួយដោយយោង គោលការណ៍ និង អនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា បានចេញសេចក្តីប្រកាសបិទ ខារ៉ាអូខេ ឬ KTV និង រោងភាពយន្ត នៅទូទាំងប្រទេស រហូតដល់ជំងឺ ខូវីដ ១៩ មានភាពធូរស្រាល ។

**ក្រសួងធម្មការ និង គណៈសង្ឃនាយក ណែនាំឱ្យប្រុងប្រយ័ត្នក្នុងពេលធ្វើបុណ្យ**

មិនទាន់ដល់ថ្នាក់ហាមឃាត់ទាំងស្រុងក្នុងការធ្វើបុណ្យទានទេ ពោលគឺពុទ្ធបរិស័ទ ក៏ដូចជាបរិស័ទ នៃ សាសនាផ្សេងៗ នៅអាចប្រតិបត្តិពិធីសាសនារបស់ខ្លួនបាន ប៉ុន្តែរាល់ការជួបជុំ ដូចជាពិធីធ្វើបុណ្យទាន ជាដើម ត្រូវមានការយល់ដឹង និង អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធីការពារពីការឆ្លងជំងឺ ខូវីដ ១៩ ដូចជាសម្អាតដៃ អនាម័យ និង សុវត្ថិភាពចំណីអាហារជាដើម ។ ជាងនេះទៅទៀត ពេលជួបជុំក្នុងពិធីបុណ្យទានជាដើម ត្រូវនៅឱ្យឃ្លាតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតពីចន្លោះ ១ ម៉ែត្រកន្លះ ទៅ ២ ម៉ែត្រ ដែលក្នុងន័យនេះ បានសេចក្តីថា ប្រសិនបើអាចកាត់បន្ថយការជួបជុំ និង ចំនួនមនុស្សចូលរួម ក៏ជាការប្រសើរ ។ នេះបើតាមឯកឧត្តម សេង សុមុនី អ្នកនាំពាក្យក្រសួងធម្មការ និង សាសនា ។

នៅថ្ងៃនេះដែរ គណៈសង្ឃនាយក នៃ ព្រះរាជាណាចក្រកម្ពុជា បានចេញសេចក្តីប្រកាសមួយមាន ៥ ចំណុច ណែនាំព្រះមេគណ អនុគណ ព្រះចៅអធិការ និង ព្រះសង្ឃពុទ្ធបរិស័ទទូទាំងប្រទេសដែលមានខ្លឹមសារថា ៖

១. ត្រូវស្វែងយល់អំពីវីរុស ខូវីដ ១៩ នេះ ដូចជាតាមរយៈការមើល ការស្តាប់ជាដើម ដែលផ្សព្វផ្សាយដោយស្ថាប័នសុខាភិបាលជាតិ អន្តរជាតិ ។

២. នៅថ្ងៃ ១៥ រោច ខែ ផល្គុន ត្រូវនឹងថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០ វេលាម៉ោង ៣ : ០០ រសៀល សូមគ្រប់វត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ទូងស្គរឱ្យបានព្រមគ្នា និង ប្រកាសសូធ្យព្រះធម៌ ដូចដែលព្រះអានន្ទ បានធ្វើហើយក្នុងសម័យពុទ្ធកាល ។ ប៉ុន្តែមិនចាំបាច់ប្រមូលមនុស្សម្នាឱ្យជួបជុំគ្នាច្រើពេកទេ ជាពិសេសហាមឃាត់អ្នកដែលមានការពាក់ព័ន្ធជាមួយអ្នកបានឆ្លង វីរុសចូវីដ ១៩ នេះ ។

៣. ត្រូវបន្តផ្សព្វផ្សាយតាមគ្រប់រូបភាពដែលអាចធ្វើបាន ដូជាតាមរយៈការទេសនា ការចែកចាយសារអប់រំដែលផលិតដោយស្ថាប័នសុខាភិបាលជាតិ អន្តរជាតិ ដល់គ្រប់ពុទ្ធបរិស័ទចំណុះជើងវត្ត ។

៤. ត្រូវប្រកាន់យកនូវការអនុវត្តន៍អនាម័យស្អាតជានិច្ច និង សុវត្ថិភាពចំណីអាហារគ្រប់ពេលវេលា ។

៥. ប្រសិនបើជួបអ្នកជំងឺដែលអាការៈដូចជា ៖ គ្រុនក្តៅ ក្អក កណ្តាស់ ផ្តាសាយ ហៀរសំបោរ ឬ ឈឺបំពង់ ក ត្រូវជួយបញ្ជូន

ទៅរកមណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បី ទទួលពិនិត្យ និង ព្យាបាលជាបន្ទាន់ ។

**ចិន ប្រកាសផ្តល់ថ្នាំ ខូវីដ ១៩ សម្រាប់មនុស្ស ២ ០០០ នាក់ និង សម្ភារផ្សេងៗ**

ម៉ោង ប្រមាណជា ១១ ព្រឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២០ )ទំព័រហ្វេសប៊ុក ស្ថានទូត ចិន ប្រចាំកម្ពុជា បានបង្ហោះសារ ដ៏គួររំភើប ១ ថា “ តាមការប៉ាន់ស្មានទុកមុន នារាត្រីថ្ងៃទី១៧ ខែ មីនា សារជាតុ Detection Reagent ជំងឺវីរុស COVID-19សម្រាប់២ ០០០ នាក់ ដែលជាជំនួយរបស់ភាគីចិនជូនចំពោះភាគីកម្ពុជានឹងមកដល់រាជធានីភ្នំពេញតាមជើងហោះហើរ ហើយជំនួយសារជាតុទាំងនេះនឹងត្រូវបានទទួលដោយក្រសួងសុខាភិបាល នៃប្រទេសកម្ពុជា ។ ប្រទេស ចិន នឹងបន្តផ្តល់ជំនួយជាសម្លៀកបំពាក់ការពារ ម៉ាសវេជ្ជសាស្ត្រ និង សម្ភារៈផ្សេងទៀតជាបន្តបន្ទាប់ និងព្រមទាំងខិតខំផ្តល់ជាកម្លាំងជំរុញគាំទ្រក្នុងកិច្ចទប់ស្កាត់នឹងជម្ងឺវីរុស ជូនចំពោះភាគីកម្ពុជា “ ។

សារដ៏ខ្លីផ្ទុកទៅដោយអត្ថន័យយ៉ាងធំធេង ខណៈកំពុងជួបប្រទះបញ្ហាជំងឺ ខូវីដ ១៩ នេះ ត្រូវបានសាទរយ៉ាងខ្លាំងពីអ្នកប្រើប្រាស់ហ្វេសប៊ុក ដោយបានចូល Comment ដូចជាថា “ បងប្អូនល្អ ! អរគុណបំផុត ! សូមអរគុណជាអនេក ដល់មហាមិត្តចិន ! សូមអរគុណជាអនេកចំពោះប្រជាជន និង រដ្ឋាភិបាល ចិន ជាដើម ៕ Kh

